**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១០៥ អនក្រ.បក

# អនុក្រឹត្យ

## ស្ដីពី

## ការកាត់ដីសរុបទំហំ ៨០០ ហិកតា នៅក្រុងប៉ៃលិន ខេត្តប៉ៃលិន ចេញពីតំបន់ព្រៃឈើបំរុងពូជបេង និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋចំនួន ១៧៥ គ្រួសារ ព្រមទាំងផ្ដល់សិទ្ធិជាកម្មសិទ្ធិលើក្បាលដី

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យ ប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីព្រៃឈើ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ ២០១៦ ស្ដីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្ដីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការបង្កើត និងកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្ដីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្ដីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្ដីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ៦១៨ /១៦ ល.ស ចុះថ្ងៃទី ០៤ ខែ តុលា ឆ្នាំ ២០១៦ របស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តប៉ៃលិន
- លិខិតលេខ ៣៩៦៧ កសក ចុះថ្ងៃទី ០៩ ខែ ឧសភា ឆ្នាំ ២០១៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

# សម្រេច

**មាត្រា ១** : ត្រូវបានកាត់ផ្ទៃដីទំហំ ៨០០ ហិកតា ចេញពីតំបន់ព្រៃឈើបំរុងពូជបេង និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ជាំជុះជាក់ស្ដែងង នៅភូមិក្បាលព្រលាន សង្កាត់អូរតាវ៉ៅ ភូមិទឹកផុស និងភូមិពេជ្រគិរី សង្កាត់ប៉ៃលិន ក្រុងប៉ៃលិន ខេត្តប៉ៃលិន តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាន និយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

**មាត្រា ២** : ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុងមាត្រា១ ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តប៉ៃលិន ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនប្រជាពលរដ្ឋ ចំនួន ១៧៥ គ្រួសារ នៅភូមិក្បាលព្រលាន សង្កាត់អូរតាវ៉ៅ ភូមិទឹកផុស និងភូមិពេជ្រគិរី សង្កាត់ប៉ៃលិន ក្រុងប៉ៃលិន ខេត្តប៉ៃលិន ។

**មាត្រា ៣** : ផ្ដល់សិទ្ធិជាកម្មសិទ្ធិឯកជន ជូនប្រជាពលរដ្ឋ ១៧៥ គ្រួសារ នៅភូមិក្បាលព្រលាន សង្កាត់អូរតាវៅ ភូមិទឹកផុស និងភូមិពេជ្រគិរី សង្កាត់ប៉ៃលិន ក្រុងប៉ៃលិន ខេត្តប៉ៃលិន ។

**មាត្រា ៤** : ក្នុងពេលដំណើរការវាស់វែង និងបែងចែកជាក់ស្ដែង គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តប៉ៃលិន ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ ជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម នៅក្នុងមូលដ្ឋាន ។

**មាត្រា ៥** : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៦** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តប៉ៃលិន ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែកក្កដា ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៦*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*